# សិក្ខាសាលាស្តីពី
# ហិរញ្ញវត្ថុនយោបាយសម្រាប់ការឃោសនាបោះឆ្នោត

*ក្រុមការងារហិរញ្ញវត្ថុនយោបាយ រួមមាន គណៈកម្មាធិការខុមហ្វ្រែល អង្គការនិកហ្វិច អង្គការដ្រាក និង សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម មានកិត្តិយសសូមជម្រាបជូនដំណឹង និងគោរពអញ្ជើញ លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ក្រុមការងារហិរញ្ញវត្ថុនយោបាយ នឹង បន្តរៀបចំសិក្ខាសាលា ស្តីពី «ហិរញ្ញវត្ថុនយោបាយសម្រាប់ការឃោសនាបោះឆ្នោត» ចំនួន ២ ខេត្ត នៅក្នុងខេត្ត តាកែវ និង ខេត្តព្រះសីហនុ ដោយមានការចូលរួមពីអ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានអាសនៈ នៅក្នុងរដ្ឋសភា អាជ្ញាធរ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ។*

*សិក្ខាសាលានេះ រៀបចំឡើងដើម្បីផ្សព្វផ្សាយដល់សាធារណជន និងភាគីពាក់ព័ន្ធ អំពីទស្សនទានទូទៅនៃ ហិរញ្ញវត្ថុនយោបាយសម្រាប់ការឃោសនាបោះឆ្នោត ឥទ្ធិពលហិរញ្ញវត្ថុនយោបាយទៅលើការបោះឆ្នោត សារៈ សំខាន់នៃការបង្កើតច្បាប់ហិរញ្ញវត្ថុនយោបាយសម្រាប់ការឃោសនាបោះឆ្នោត និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ហិរញ្ញវត្ថុនយោបាយសម្រាប់ការឃោសនាបោះឆ្នោត។*

*សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី អ្នកនាង កញ្ញា តំណាងសារព័ត៌មាន ជាតិ និងអន្តរជាតិ សូមចូលរួមយកព័ត៌មានតាមការគួរ។*

*សូមអរគុណ !*

***ទីកន្លែង និងកាលបរិច្ឆេទ រៀបចំសិក្ខាសាលា***

| ***កាលបរិច្ឆេទ*** | ***ខេត្ត*** | ***ទីកន្លែង*** |
|---|---|---|
| ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២ | ខេត្តតាកែវ | នៅសាលប្រជុំ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ |
| ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១២ | ខេត្តព្រះសីហនុ | នៅសណ្ឋាគារ និងរមណីយដ្ឋានលើភ្នំ |


*<u>សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង</u> ៖*

*១-គណៈកម្មាធិការខុមហ្វ្រែល (០៩៧-៩៩-៨៧-២៦៥) ឬ ២-អង្គការនិចហ្វិច (០៩២-១៥៥-៦១៥)*